**DHS Multicultural Services**
**KHMER**

ព័ត៌មានដូចតទៅនេះ នាំមកជូនដោយ Centrelink

តើអ្នកដឹងទេថា អ្នកអាចទទួលបានព័ត៌មានជាភាសាខ្មែរអំពីប្រាក់ឧបត្ថម្ភ និងសេវាផ្សេងៗពី Department of Human Services ?

**បាទ/ចាស៎, មានពេលខ្លះ ខ្ញុំឮព័ត៌មានជាភាសាខ្មែរអំពីប្រាក់ឧបត្ថម្ភ និងសេវាផ្សេងៗតាមវិទ្យុ។ តើខ្ញុំអាចរកព័ត៌មាននៅកន្លែងណាទៀត?**

បាទ/ចាស៎, អ្នកអាចរកព័ត៌មានដែលគេបកប្រែហើយនៅលើវ៉ិបសាយថ៍របស់ក្រសួង Human Services ដែលមានច្រើនភាសា។ នៅទីនោះរួមមានព័ត៌មានអំពីប្រាក់ឧបត្ថម្ភរបស់ Centrelink, សេវា Child Support និងសេវា Medicare។

នៅពេលដែលអ្នកទូរស័ព្ទទៅក្រសួងនេះ ឬទៅ Service Centre ដោយផ្ទាល់ អ្នកអាចស្នើសុំនិយាយជាមួយបុគ្គលិកជាភាសាខ្មែរបាន។ ក្រៅពីនេះ អ្នកក៏អាចនិយាយជាមួយនឹងបុគ្គលិកអំពីប្រាក់ឧបត្ថម្ភ ឬសេវារបស់ Centrelink ជាភាសាខ្មែរតាមរយៈការទូរស័ព្ទទៅលេខ **131 202** បានផងដែរ។

ហើយនៅពេលដែលក្រសួងសុំមើលឯកសារផ្ទាល់ខ្លួនដូចជាសំបុត្រកំណើត គេអាចបកប្រែឯកសារនោះជាភាសាអង់គ្លេសជូនអ្នកបាន។ សេវាទាំងនេះមានបម្រើជូនដោយឥតគិតថ្លៃ។

**តើក្រសួងមានវិធានការអ្វីខ្លះដើម្បីស្វែងយល់អំពីតម្រូវការសហគមន៍របស់ខ្ញុំ?**

ក្រសួងមានបុគ្គលិកជំនាញប្រហែលជា៧០នាក់ដែលបម្រើការនៅក្នុងសហគមន៍ពហុវប្បធម៌ ហើយពួកគេជួយសហគមន៍ឲ្យអាចទទួលបាននូវប្រាក់ឧបត្ថម្ភ និងសេវាផ្សេងៗដែលមានជូន។ គេហៅបុគ្គលិកទាំងនោះថាជា Multicultural Service Officers។

ក្រសួងក៏មានបុគ្គលិកដែលមានប្រវត្តិ, ចំណេះដឹង និងជំនាញចម្រុះជាច្រើនផងដែរ ហើយមិនតែប៉ុណ្ណោះក៏មានបុគ្គលិកដែលនិយាយ២ភាសាទៀតផង។ ការមានបុគ្គលិកចម្រុះបែបនេះ ជួយដល់ក្រសួងឲ្យយល់អំពីកាលៈទេសៈ និងតម្រូវការរបស់អតិថិជនម្នាក់ៗ ហើយដើម្បីធានាឲ្យបានថា បុគ្គលិកដែលនិយាយភាសាខ្មែរគឺមានប្រចាំជាប់ជានិច្ច។

**យី, ពិតជាល្អណាស់នេះ! អ៊ីចឹង ប្រសិនបើខ្ញុំទៅ Service Centre ឬទូរស័ព្ទទៅក្រសួង ខ្ញុំអាចស្នើសុំនិយាយជាមួយបុគ្គលិកដែលចេះភាសាខ្មែរបានឬ?**

បាទ/ចាស៎ ពិតជាបាន, ហើយប្រសិនបើគ្មានបុគ្គលិកដែលនិយាយភាសាខ្មែរទេនោះ គេក៏មានផ្តល់ជូនអ្នកបកប្រែផងដែរណា។

ហើយសូមកុំភ្លេចថា អ្នកអាចរកព័ត៌មានជាភាសារបស់អ្នកបាននៅលើវ៉ិបសាយថ៍ **humanservices.gov.au** តាមរយៈការចុចត្រង់ប៊ូតុងភាសា។

**ចុះបើខ្ញុំមានសំណួរណាមួយអំពីប្រាក់ឧបត្ថម្ភ ឬសេវារបស់ Centrelink, តើមានលេខទូរស័ព្ទដែលខ្ញុំអាចទូរស័ព្ទទៅ ដើម្បីនិយាយជាមួយបុគ្គលិកជាភាសាខ្មែរបានទេ?**

បាទ/ចាស៎ ពិតជាមាន - គ្រាន់តែចុចលេខ **131 202** ហើយនិយាយថា ខ្មែរទៅបានហើយ។ គេនឹងភ្ជាប់ខ្សែទូរស័ព្ទអ្នកទៅបុគ្គលិកដែលនិយាយភាសាខ្មែរ។ ម្តងទៀតលេខទូរស័ព្ទគឺ **131 202** ។

ថ្លៃសេវាទូរស័ព្ទអាចមានថ្លៃខុសៗគ្នា អាស្រ័យទៅលើក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ។ ការហៅពីទូរស័ព្ទចល័ត ឬពីទូរស័ព្ទសាធារណៈ អាចមានតម្លៃខ្ពស់ជាងធម្មតា។

Australian Government
Department of Human Services

## Multicultural Services

**Person 1:** Did you know you can get information about payments and services from the Department of Human Services in Khmer

**Person 2: Yes, sometimes I hear information in Khmer about payments and services on the radio. Where else can I get information?**

**Person 1:** Well, you can find translated information on the Human Services website in many languages. This includes information about Centrelink payments, Child Support services and Medicare services.

When you call the department or visit a service centre, you can ask to speak to someone in Khmer. You can also speak to someone about a Centrelink payment or service in Khmer by calling **131 202**.

And, if the department asks to see a personal document, like a birth certificate, they can translate it into English for you. These services are free of charge.

**Person 2: What does the department do to understand my community's needs?**

**Person 1:** The department has around 70 specialist staff that work with multicultural communities and help them access payments and services. They are called Multicultural Service Officers.

The department also employs staff from diverse backgrounds and bilingual staff. This helps the department to understand their customers' individual needs and circumstances, and ensures someone who speaks Khmer is never far away.

**Person 2: Wow, that's great! So if I go to a Service Centre, or call the department, I can ask for someone who speaks Khmer?**

**Person 1:** Yes. If there isn't a staff member that speaks Khmer, an interpreter will be provided.

And, don't forget you can find translated information at **humanservices.gov.au** by clicking the language button.

**Person 2: And if I have a question about Centrelink payments or services, there's a number I can call to speak to a staff member in Khmer.**

**Person 1:** That's right – just call **131 202** and say' Khmer'. You will be put through to someone who speaks Khmer**.** That's **131 202.**

Call charges may vary depending on the telephone service provider. Calls from public telephones and mobile phones may be charged at a higher rate.